**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ០៤

ចុះថ្ងៃទី ១៤ខែ មករាឆ្នាំ២០០០

សាលដីកា

លេខ ៣២

ចុះថ្ងៃទី ១២ខែ កក្កដាឆ្នាំ២០០០

**នាមនាមប្រជារាស្ត្រខ្មែរ**

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១២ខែ កក្កដាឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៤- លោក ស៊ិន ឌឹម ចៅក្រម

៥- លោក យស់ ស្វូខឿន ចៅក្រម

ក្រឡាបញ្ជី

លោក វ៉ាន់ ប៊ូរ៉ាត

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២ ខែ មិថុនាឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ០៤ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

ពីបទ : ក្លែងបន្លំហត្ថលេខាលើកិច្ចសន្យា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៣-១១-៩៤ តាមបញ្ញត្តិមាត្រា ៤៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិ ខ្មែរ កើតនៅ ភូមិជីផដ្ឋ ស្រុកគៀនស្វាយ ខេត្តកណ្តាល របររកស៊ី នាយកសាលាចំណេះទូទៅឯកជនសំពៅមាស មានទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះលេខ ១០ ក្រុម ៥២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ នូ សាម៉េត " រស់ " ម្តាយឈ្មោះអ៊ុច ចាន់ថៃ " រស់ " ប្រពន្ធឈ្មោះ ស កិនសុគន្ធី មានកូន ៤នាក់ ។ ក្រៅឃុំ ។

មេធាវី លោក ដួង លឿង ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុន គឹមសុង ( ស្លាប់ ) " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើការនៅក្រសួងពាណិជ្ជកម្ម មានទីលំនៅ ផ្ទះលេខ ១១១E០

ក្រុម៣៦ ផ្លូវលេខ ១០៥ សង្កាត់បឹងកេងកង III ខណ្ឌចំការមន ក្រុងភ្នំពេញ ។

បានផ្ទេរសិទ្ធិឱ្យឈ្មោះនេត វណ្ណៈ អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ១៣៨E០ ផ្លូវ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មេធាវីគ្មាន

តាមបណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់លោកមេធាវី សោម ច័ន្ទឌីណា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី១៥-១១-៩៤ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុន គឹមសុង ប្តឹងពីឈ្មោះ នូ សុវណ្ណារ៉ា ពីបទៈ ក្លែងហត្ថលេខាលើកិច្ចសន្យា ដោយយកសណ្ឋាគារច័ន្ទរះ ជាកម្មសិទ្ធិរបស់ខ្លួនទៅជួយឱ្យអ្នកដទៃ ដោយសំអាងថា ខ្លួនបានចូលភាគហ៊ុនធ្វើអាជីវកម្មរួមគ្នា នោះពុំពិតទេ ។

ដូច្នេះ ខ្លួនសុំប្តឹងឱ្យឈ្មោះ នូ សុវណ្ណារ៉ា សងការខូចខាត សណ្ឋាគារច័ន្ទរះ តាមការជាក់ស្តែង ។

- សេចក្តីសន្និដ្ឋានរបស់ តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ថា : សំរេចចោទប្រកាន់លើឈ្មោះ នូ សុវណ្ណារ៉ា ពី បទ : ក្លែងលិខិតពាណិជ្ជកម្ម ក្នុងគោលបំណងឆបោកទ្រព្យសម្បត្តិអ្នកដទៃ កាលពីថ្ងៃទី ០៥-៨-៩៤ តាមមាត្រា ៥០, ៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ១៤ " ខ " ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១- ផ្តន្ទាទោសឈ្មោះ នូ សុវណ្ណារ៉ា ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ពិន័យជាប្រាក់ចំនួន ៨លានរៀល និង សងជម្ងឺចិត្តចំនួន ៣ពាន់ដុល្លាអាមេរិក ទៅឈ្មោះ ស៊ុន គឹមហុង ពីបទក្លែងលិខិតឯកជន និង ឆបោក សំណូមពរលើសពីនេះ បដិសេធចោល ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់លេខ ១៦ " ខ " ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ១៩៩៦ របស់ឈ្មោះ នូ សុវណ្ណារ៉ា ដែលប្តឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤ " ខ " ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៧ " ខ " ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១- តម្កល់សាលក្រមលេខ ១៤ " ខ " ចុះថ្ងៃទី ២៣-០៤-៩៦ ទុកជាបានការពេញទាំងមូល បើមិនព្រមសង បង្ខាប់ដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជន

ជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៥ " ខ " ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៦ របស់ឈ្មោះ នូ សុវណ្ណារ៉ា ដែលប្តឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ " ខ " ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាង មហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

១- ទទួលបណ្តឹងឧទ្ធរណ៍ របស់ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤ " ខ " ចុះថ្ងៃទី ២៣-៤-៩៦ និង សាលក្រមលេខ ៤៧ " ខ " ចុះថ្ងៃទី ១០-៩-៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល តែត្រូវបន្ថែមបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ តាមមាត្រា ៥២ និង សំរេចប្រាក់ពិន័យឱ្យដាច់ដោយឡែកពីប្រាក់ជម្ងឺចិត្ត ។

- បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ ១៣៧ ចុះថ្ងៃទី ២៧ខែ មិថុនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៦ របស់ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខ្វះមូលដ្ឋានច្បាប់ ។

២- តំកល់សាលក្រមព្រហ្មទណ្ឌលេខ៤៧ ( ខ ) ចុះថ្ងៃទី ១០-៩-៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខគូក្តី បើកផ្លូវប្តឹងទាស់ និង សាទុក្ខ ក្នុងកំណត់ច្បាប់ ។

៤- សាលដីកានេះ ជំនុំជំរះ ចំពោះមុខជនជាប់ចោទទាំង ៤នាក់ ចំពោះមេធាវី ការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី ការពារជនជាប់ចោទទាំង ៤ និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់ ឈ្មោះ សោម ច័ន្ទឌីណា មេធាវីការពារជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៣៧ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់លោក មេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខ្វះមូលដ្ឋានច្បាប់ ។

២-	ទទួលពាក្យសុំពន្យាពេលសវនាការ ចុះថ្ងៃទី ២៣-៧-៩៧ និងការសុំពន្យាពេលសវនាការ របស់លោក មេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

៣-	តម្កល់សាលដីកាព្រហ្មទណ្ឌ កំបាំងមុខលេខ ១៣៧ ចុះថ្ងៃទី ២៧-៦-៩៧ របស់សាលា ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៤-	សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

-	បានឃើញបណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ លោក សោម ច័ន្ទឌីណា មេធាវីការពារជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៣៤ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-	បានឃើញសារណា ចុះថ្ងៃទី ២០ខែ មេសាឆ្នាំ ២០០០ របស់ឈ្មោះ នូ សុវណ្ណារ៉ា " ម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-	បានឃើញសារណាតប ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០០ របស់ឈ្មោះ នេត វណ្ណៈ " ចុងបណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-	បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-	បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១-	បណ្តឹងសាទុក្ខរបស់លោក សោម ច័ន្ទឌីណា ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

២-	តម្កល់សាលដីកា ព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២-៦-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-	ក្រឡាបញ្ជីអានសារណារបស់ជនជាប់ចោទ

-	បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ នេត វណ្ណៈ " ជាចុងបណ្តឹងសាទុក្ខ " នាពេល ជំនុំជំរះថា : សូមគោរពក្រុមប្រឹក្សាជំនុំជំរះ ខ្ញុំបាទសូមរក្សាចម្លើយរបស់ខ្ញុំបាទនៅក្នុងសារណា ចុះថ្ងៃទី ០៥-៥-២០០០ នៅដដែល ។

-	បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ដួង លឿង ជាមេធាវី ការពារឱ្យជនជាប់ចោទ ឈ្មោះ នូ សុវណ្ណារ៉ា ( ជាម្ចាស់បណ្តឹងសាទុក្ខ ) នៅពេលជំនុំជំរះថា : ខ្ញុំទើបបានដាក់ពាក្យការពារ នៅ ថ្ងៃទី ០៥-៧-០០ មិនបានពិនិត្យសំណុំរឿងសព្វគ្រប់ទេ ហេតុនេះ ខ្ញុំសូមលើកឡើងនូវពីរចំណុច :

+ ទីមួយ : ការសុំចោទប្រកាន់ជាផ្លូវការ មិនមានលិខិតឆ្លើយតប ពីក្រសួងសាម៉ីទេ ។

+ ទីពីរ : នៅក្នុងសំណុំរឿងមានបាត់ឯកសារមួយចំនួន និង ខ្សែអាត់ ដែលជាសំអាង របស់ នូ សុវណ្ណារ៉ា ។ ក្នុងរឿងនេះ ដំបូង នូ សុវណ្ណារ៉ា បានប្តឹងឈ្មោះ ស៊ិន គីមសុង ពីបទក្លែងបន្លំ

ឯកសារ និង រំលោភលើទំនុកចិត្ត តែបែរជា ស៊ិន គីមសុង ប្ដឹង នូ សុវណ្ណារ៉ា ពីបទនេះវិញដែល ។ សូមតុលាការពិចារណា ។

- តំណាងមហាអយ្យការ សូមតម្កល់សេចក្ដីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៥២ ចុះថ្ងៃទី ០៤-៦-៩៩ របស់លោក សោម ច័ន្ទឌីណា មេធាវីការពារឱ្យជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បាន តាមមាត្រា ១៤ នៃច្បាប់ ស្ដីពី ការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទឈ្មោះ នូ សុវណ្ណារ៉ា ក្នុងសារណា ចុះថ្ងៃទី ២០-៤-២០០០ ថា ដំណើរការអាជីវកម្មរបស់ខ្លួន លើភោជនីយដ្ឋាន ក៏ដូចសណ្ឋាគារច័ន្ទរះ កន្លងមកធ្វើដោយមានច្បាប់ទំលាប់ត្រឹមត្រូវ ដោយមានការឯកភាពពីម្ចាស់ភាគហ៊ុន ទាំងអស់ ហើយបានចុះកិច្ចសន្យាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី ៣០-៧-៩៤ និង កិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ ដែលមានហត្ថលេខារបស់លោក ស៊ិន គីមសុង ប្រាកដមែន នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

\+ លោក ស៊ិន គីមសុង ក្ដី លោក នេត វណ្ណៈ ក្ដី និង សមាជិកភាគហ៊ុនឯទៀតក្ដី របស់សណ្ឋាគារច័ន្ទរះសុទ្ធតែបានបដិសេធថា ពុំបានជួលសណ្ឋាគារច័ន្ទរះឱ្យឈ្មោះនូ សុវណ្ណារ៉ា ធ្វើអាជីវកម្មឡើយ ។

\+ កិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ រវាងឈ្មោះ ស៊ិន គីមសុង និង ឈ្មោះ នូ សុវណ្ណារ៉ា ដែលឈ្មោះ នូ សុវណ្ណារ៉ា អះអាងថា ពិតជាលោក ស៊ិន គីមសុង បានចុះហត្ថលេខា ព្រមព្រៀងជួលសណ្ឋាគារច័ន្ទរះឱ្យខ្លួននោះ ត្រូវបានស្ថាប័នមានសមត្ថកិច្ច គឺការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រនៃ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និង ការិយាល័យកោសល្យវិច្ឆ័យប្រព៉េណី នៃនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ របស់ក្រសួងមហាផ្ទៃ បញ្ជាក់តាមលទ្ធផលកោសល្យវិច្ឆ័យលេខ ០១៩ កសវច.៩៥ ចុះថ្ងៃទី០៩-១០-៩៥ និងតាមប្រកាសលទ្ធផលកោសល្យវិច្ឆ័យលេខ៤៣/៩៦ ឋ.ខ ចុះថ្ងៃទី ១២-៦-៩៦ ថា ហត្ថលេខារបស់ឈ្មោះ ស៊ិន គីមសុង នៅក្នុងកិច្ចសន្យា ចុះថ្ងៃទី ០៥-៨-៩៤ ជាហត្ថលេខាក្លែងបន្លំពិតប្រាកដ ។

- យល់ឃើញថា ផ្អែកតាមកិច្ចសន្យាក្លែងបន្លំនេះ ឈ្មោះ នូ សុវណ្ណារ៉ា បានតាំងខ្លួនជាម្ចាស់សណ្ឋាគារ ហើយជួលសណ្ឋាគារច័ន្ទរះ បន្តទៅឱ្យជនម្នាក់ទៀតឈ្មោះ ចាន់ ស៊ីឡុង តាមកិច្ចសន្យាចុះថ្ងៃទី ១២-១០-៩៤ ដែលបណ្ដាលឱ្យមានព្យសនកម្ម ដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាម្ចាស់សណ្ឋាគារ ។

- យល់ឃើញថា ជនជាប់ចោទ បានធ្វើសារណាជូនមកតុលាការកំពូលហើយ។ ក៏បានទទួល

ដីកាកោះដែរ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា កាលើកឡើងរបស់មេធាវីជនជាប់ចោទនាសវនាការថា ព្រះរាជអាជ្ញាចោទប្រកាន់ជនជាប់ចោទ ដោយពុំបានទទួលការអនុញ្ញាតពីក្រសួងការពារជាតិនោះ គឺជាការភ័ន្តច្រឡំ តាមពិតតាមលិខិតលេខ ២៥០/៩៦ សជណ ចុះថ្ងៃទី ៣-១០-៩៦ ក្រសួងការពារជាតិបានអនុញ្ញាតឱ្យធ្វើការចោទប្រកាន់លើឈ្មោះ នូ សុវណ្ណារ៉ា ហើយ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌ លេខ ១៣៤ ចុះថ្ងៃទី ០២-៦-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី**

**កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ០៤-៦-៩៩ របស់លោក សោម ច័ន្ទឌីណា មេធាវីការពារឱ្យជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៣៤ ចុះថ្ងៃទី ០២-៦-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០។